ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# របាយការណ៍
# ស្តីពីលទ្ធផលអង្កេតពីភាពមានការងារធ្វើ
# របស់និស្សិតនៅ ស.ភ.ន.វ.ស


បណ្ឌិត ថ៉ាន់ ស៊ុនដេត　　ស្ងួន ចំរើន



ភ្នំពេញ ខែ មិនា ឆ្នាំ ២០១៦

បោះពុម្ពដោយ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# មាតិកា


មាតិកា....................i

១. សេចក្តីផ្តើម....................1

២. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ....................2

៣. លទ្ធផលនៃការវិភាគសម្រាប់ថ្នាក់បរិញ្ញាបត្រ....................3

៣.១. វិភាគភាពមានការងារធ្វើ តាមមុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................3

៣.២. ភាពមានការងារធ្វើ ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................4

៣.២.១. ការវិភាគភាពមានការងារធ្វើ តាមវិស័យ និងជំនាញឯកទេស....................4

៣.២.២. ការវិភាគភាពមានការងារធ្វើ តាមភេទ និងជំនាញឯកទេស....................5

៣.២.៣. ការវិភាគភាពមានការងារធ្វើ តាមភេទ និងវិស័យ....................6

៣.៣. ភាពមានការងារធ្វើត្រូវជំនាញឯកទេស ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................7

៣.៤. កម្រិតប្រាក់បៀវត្ស ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................9

៣.៤.១. ការវិភាគកម្រិតប្រាក់បៀវត្ស តាមភេទ....................9

៣.៤.២. ការវិភាគកម្រិតប្រាក់បៀវត្ស តាមជំនាញឯកទេស....................11

៣.៤.៣. កម្រិតប្រាក់បៀវត្សនៃការងារត្រូវនឹងជំនាញឯកទេស....................12

៣.៥. ការលើកកម្ពស់កម្រិតជីវភាព ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................12

៣.៦. និស្សិតដែលបានបន្តការសិក្សា ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ....................13

៤. លទ្ធផលនៃការវិភាគសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់....................16

៤.១. ការវិភាគភាពមានការងារធ្វើ តាមមុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់....................16

៤.២. ការវិភាគភាពមានការងារធ្វើ តាមឯកទេស....................17

៤.៣. ការវិភាគភាពមានការងារធ្វើ តាមវិស័យ....................17

៤.៤. ការវិភាគកម្រិតប្រាក់បៀវត្ស....................18

៤.៤.១. ការវិភាគកម្រិតប្រាក់បៀវត្ស មុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់....................18

៤.៤.២. ការវិភាគកម្រិតប្រាក់បៀវត្ស តាមការងារត្រូវជំនាញ និងខុសជំនាញ....................19

៤.៤.៣. ការវិភាគកម្រិតប្រាក់បៀវត្ស នៃការងារត្រូវជំនាញ និងភេទ....................19

៤.៥. ការវិភាគភាពមានការងារធ្វើត្រូវជំនាញ និងភេទ....................20

៤.៦. ការវិភាគលើការរៀនបន្តរបស់និស្សិតក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់....................21

៥. សន្និដ្ឋាន ........................................................................................................................................21
ឧបសម្ព័ន្ធ១ ........................................................................................................................................22
ឧបសម្ព័ន្ធ២ ........................................................................................................................................23

## ១. សេចក្តីផ្តើម

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (សភនវស) ត្រូវបានបង្កើតឡើងនាឆ្នាំ ១៩៤៩ ដែលកាលនោះមានឈ្មោះថា **វិទ្យាស្ថានច្បាប់ និងសេដ្ឋកិច្ច** ហើយត្រូវបានផ្លាស់ប្តូរឈ្មោះជាច្រើនលើក។ រហូតមកដល់ឆ្នាំ២០០៣ ទើបមានឈ្មោះជា**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** តាមរយៈអនុក្រឹត្យលេខ ៥៦ អនក្របក ចុះថ្ងៃទី ១៦ កក្កដា ឆ្នាំ ២០០៣។ ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ ក៏ត្រូវបានចាប់ផ្តើមឡើងវិញនៅឆ្នាំ១៩៩២ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក៏បានចាប់ផ្តើមបើកចាប់ពីឆ្នាំ២០០៣ រហូតដល់បច្ចុប្បន្ន។ បច្ចុប្បន្ន សាកលវិទ្យាល័យមានមហាវិទ្យាល័យចំនួនបួន និងថ្នាក់ក្រោយបរិញ្ញាបត្រចំនួនមួយ។

ការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រតាមមហាវិទ្យាល័យនីមួយៗមានដូចខាងក្រោម ៖

- **មហាវិទ្យាល័យនីតិសាស្ត្រ**
  - បរិញ្ញាបត្រនីតិសាស្ត្រ
  - បរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាអង់គ្លេស (ELBBL)
  - បរិញ្ញាបត្រនីតិសាស្ត្រសិក្សាជាភាសាបារាំង
- **មហាវិទ្យាល័យរដ្ឋបាលសាធារណៈ**
  - បរិញ្ញាបត្ររដ្ឋបាលសាធារណៈ និង
  - បរិញ្ញាបត្រទំនាក់ទំនងអន្តរជាតិ
- **មហាវិទ្យាល័យសេដ្ឋកិច្ច និងគ្រប់គ្រង**
  - បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍
  - បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច
  - បរិញ្ញាបត្រគណនេយ្យ
  - បរិញ្ញាបត្រធនាគារ និងហិរញ្ញវត្ថុ និង
  - បរិញ្ញាបត្រគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច
- **មហាវិទ្យាល័យសេដ្ឋកិច្ចព័ត៌មានវិទ្យា**
  - បរិញ្ញាបត្រសេដ្ឋកិច្ចព័ត៌មានវិទ្យា

ចំណែកថ្នាក់ក្រោយបរិញ្ញាបត្រ មានឯកទេសចំនួន៤ ដូចមានរាយចំនួនខាងក្រោម ៖

- បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសនីតិឯកជន
- បរិញ្ញាបត្រជាន់ខ្ពស់នីតិសាស្ត្រ ឯកទេសរដ្ឋបាលសាធារណៈ
- បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រងសហគ្រាស
- បរិញ្ញាបត្រជាន់ខ្ពស់ធុរកិច្ច ឯកទេសគ្រប់គ្រងហិរញ្ញវត្ថុ

នៅឆ្នាំសិក្សា២០១៥ - ២០១៦ ***សភនវស*** មាននិស្សិតសរុបចំនួន ១៣,៧៦៧នាក់ (នារី ៦៥៤៣នាក់) ក្នុងនោះមាននិស្សិតបរទេសចំនួន ៨០នាក់ (នារី ៣០នាក់) ដែលបាននិងកំពុងបណ្តុះបណ្តាលនៅទីនេះ។

សាកលវិទ្យាល័យមានក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ សាស្ត្រាចារ្យជាប់កិច្ចសន្យាជាតិ និងអន្តរជាតិសរុបចំនួន ៥១៣នាក់ (នារី ១១៦នាក់) ដែលបាននិងកំពុងបំរើការងារ និងបង្រៀននៅទីនេះ។

ចាប់តាំងពីឆ្នាំ១៩៨២ ដែលជាឆ្នាំនៃចាប់ផ្តើមដំណើរការឡើងវិញរបស់សាកលវិទ្យាល័យ និងរហូតមកដល់បច្ចុប្បន្ន និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សរុបមានចំនួន ៣៨,៨៦៤នាក់ (ស្រី១២៩៩១នាក់)។

បច្ចុប្បន្ន និស្សិតទាំងអស់នោះបាននិងកំពុងបំរើការងារតាមស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលនានាក្នុងទូទាំងប្រទេស។ ដោយឡែក ក្នុងចំណោមនិស្សិតខាងលើនោះក៏មាននិស្សិតបរទេសចំនួន ៨២នាក់ (ស្រី២៦នាក់) ដែលបានបញ្ចប់ការសិក្សារបស់ខ្លួនដោយជោគជ័យ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាយើងដែរ។

នៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៥ សាកលវិទ្យាល័យបានផ្តល់សញ្ញាបត្រដល់និស្សិតជ័យលាភីសរុបចំនួន៣,៧៦៩នាក់ (ស្រី១,៥៩៩នាក់) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលក្នុងនោះមាន ៖

- និស្សិតបរិញ្ញាបត្រចំនួន ៣,៤៥០នាក់ (នារី១,៥០៥នាក់)
- និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣១៩នាក់ (នារី៩៤នាក់)

ក្នុងចំណោមនិស្សិតជ័យលាភីដែលបានទទួលសញ្ញាបត្រទាំងអស់នោះ មានប្រមាណ ៩៥,៥២% មានការងារធ្វើរួចហើយ ក្នុងនោះនិស្សិតបរិញ្ញាបត្រមាន ៩៥,៥០% និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់មាន ៩៥,៧០%។

## ២. វិធីសាស្ត្រនៃការប្រមូលទិន្នន័យ

ក្នុងដំណើរការស្រាវជ្រាវលើកទី៣ ពីភាពមានការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ បានចាប់ផ្តើមពីថ្ងៃទី ១០ ដល់ ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ សម្រាប់ធ្វើការសម្ភាសន៍ចំនួនច្រើនជាង៥០% នៃនិស្សិតដែលមានក្នុងបញ្ជីឈ្មោះនិស្សិតដែលត្រូវទទួលសញ្ញាបត្រនៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៥ ។ ចំនួននិស្សិតដែលបានធ្វើការសម្ភាសន៍សរុបមានចំនួន ២៧៥២ នាក់ ដែលក្នុងនោះមាននិស្សិតថ្នាក់បរិញ្ញាបត្រចំនួន ២២៦៧ នាក់ និងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣០៣ នាក់។

ការស្រាវជ្រាវស្វែងរកព័ត៌មានទាក់ទងនឹងការទទួលបានការងារធ្វើនេះ សាកលវិទ្យាល័យបានប្រើទម្រង់សម្ភាសន៍តាមទូរស័ព្ទ ដោយយោងតាមបញ្ជីឈ្មោះនិស្សិតដែលត្រូវបានប្រកាសថាប្រឡងជាប់ជាស្ថាពរ ។ អ្នកជំនួយការធ្វើសម្ភាសន៍តាមទូរស័ព្ទមានចំនួនសរុប ២៥នាក់ ដោយសម្ភាសន៍និស្សិតបរិញ្ញាបត្រក្នុងឆ្នាំសិក្សា២០១២-២០១៣ និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ក្នុងឆ្នាំសិក្សា២០១៣-២០១៤។

ខាងក្រោមនេះ ជាតារាងសង្ខេបលទ្ធផលស្រាវជ្រាវតាមជំនាញនីមួយៗ ទាំងផ្នែកបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដែលបានចូលរួមផ្តល់បទសម្ភាសន៍ និងបំពេញកម្រងសំណួរជាមួយព័ត៌មានដែលអាចជឿជាក់បាន ៖

តារាងសង្ខេបនៃនិស្សិតមានការងារធ្វើ មុន និងក្រោយបញ្ចប់ការសិក្សា

| ល.រ | ប្រភេទនិស្សិត | ភាពមានការងារធ្វើ មុនពេលបញ្ចប់ការសិក្សា(%) | | | ភាពមានការងារធ្វើ ក្រោយពេលបញ្ចប់ការសិក្សា(%) | | |
|---|---|---|---|---|---|---|---|
| **ក** | **បរិញ្ញាបត្រឯកទេស** | តាមផ្នែក | សរុប | សរុបរួម | តាមផ្នែក | សរុប | សរុបរួម |
| ១ | នីតិសាស្ត្រ(ខេមរៈភាសា) | 15.8% | | | 91.2% | | |
| ២ | នីតិសាស្ត្រ(ភាសាបរទេស) | 18.2% | | | 88.9% | | |
| ៣ | រដ្ឋបាលសាធារណៈ | 9.8% | | | 96.0% | | |
| ៤ | សេដ្ឋកិច្ច | 11.5% | | | 98.5% | | |
| ៥ | គណនេយ្យ | 29.4% | **15.0%** | | 97.2% | **95.5%** | |
| ៦ | ធានាគារ និងហិរញ្ញវត្ថុ | 29.4% | | | 97.1% | | |
| ៧ | សេដ្ឋកិច្ចព័ត៌មានវិទ្យា | 14.1% | | **23.67%** | 98.4% | | **95.52%** |
| ៨ | គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច | 11.5% | | | | | |
| **ខ** | **បរិញ្ញាបត្រជាន់ខ្ពស់ឯកទេស** | តាមផ្នែក | សរុប | | តាមផ្នែក | សរុប | |
| ១ | នីតិឯកជន | 75.0% | | | 90.6% | | |
| ២ | នីតិរដ្ឋបាលសាធារណៈ | 78.6% | **86.4%** | | 94.3% | **95.7%** | |
| ៣ | ធុរកិច្ចឯកទេសហិរញ្ញវត្ថុ | 98.6% | | | 100.0% | | |
| ៤ | ធុរកិច្ចឯកទេសគ្រប់គ្រងសហគ្រាស | 98.4% | | | 100.0% | | |

# ៣. លទ្ធផលនៃការវិភាគសម្រាប់ថ្នាក់បរិញ្ញាបត្រ

## ៣.១. វិភាគភាពមានការងារធ្វើ តាមមុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

តារាង៣.១៖ ការវិភាគភាពមានការងារធ្វើ តាមមុន និងក្រោយបញ្ចប់បរិញ្ញាបត្រ

| ភាពមានការងារធ្វើ | | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| មុនសិក្សាថ្នាក់បរិញ្ញាបត្រ | **ចំនួន** | 190 | 136 | **326** |
| | **%** | 58.3% | 41.7% | **100.0%** |
| ក្រោយបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | **ចំនួន** | 1091 | 881 | **1972** |
| | **%** | 55.3% | 44.7% | **100.0%** |

តាមតារាង៣.១ ខាងលើបានបង្ហាញថា៖ ក្នុងចំណោមនិស្សិតដែលមានការងារធ្វើ មុនពេលចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងនោះនិស្សិតប្រុសមានការងារធ្វើ

ចំនួន១៩០នាក់ ឬ៥៨.៣% និងនិស្សិតស្រីមានការងារធ្វើចំនួន ១៣៦នាក់ ឬ៤១.៧%។ ម្យ៉ាងទៀតអ្វីដែលគួរឲ្យកត់សំគាល់នោះគឺចំនួននិស្សិតដែលមានការងារធ្វើ ក្រោយបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ មានចំនួនកើនឡើងខ្លាំង ដែលក្នុងនោះនិស្សិតប្រុសមានការងារធ្វើចំនួន ១០៩១នាក់ ឬ ៥៤.៣% និងនិស្សិតស្រីមានការងារធ្វើចំនួន ៨៨១នាក់ ឬ ៤៥.៧%។

## ៣.២. ភាពមានការងារធ្វើ ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

### ៣.២.១. ការវិភាគភាពមានការងារធ្វើ តាមវិស័យ និងជំនាញឯកទេស

តារាង៣.២.១៖ ភាពមានការងារធ្វើ វិភាគតាមវិស័យ និងជំនាញ

| បរិញ្ញាបត្រ ឬជំនាញ | | ការងារតាមវិស័យ | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|
| | | ការងាររដ្ឋ | ការងារឯកជន | ការងារអង្គការ | គ្មានការងារ | និស្សិត | អាជីវកម្មផ្ទាល់ខ្លួន | ការងារផ្សេងៗ | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 246 | 207 | 29 | 38 | 16 | 60 | 15 | 611 |
| | % | 40.3% | 33.9% | 4.7% | 6.2% | 2.6% | 9.8% | 2.5% | 100% |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 19 | 21 | 7 | 4 | 2 | 1 | 0 | 54 |
| | % | 35.2% | 38.9% | 13.0% | 7.4% | 3.7% | 1.9% | 0.0% | 100% |
| រដ្ឋបាលសាធារណៈ | ចំនួន | 27 | 10 | 2 | 2 | 0 | 1 | 8 | 50 |
| | % | 54.0% | 20.0% | 4.0% | 4.0% | 0.0% | 2.0% | 16.0% | 100% |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 56 | 338 | 8 | 6 | 1 | 70 | 1 | 480 |
| | % | 11.7% | 70.4% | 1.7% | 1.3% | 0.2% | 14.6% | 0.2% | 100% |
| គណនេយ្យ | ចំនួន | 15 | 102 | 8 | 3 | 1 | 12 | 0 | 141 |
| | % | 10.6% | 72.3% | 5.7% | 2.1% | 0.7% | 8.5% | 0.0% | 100% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 67 | 481 | 35 | 17 | 3 | 78 | 10 | 691 |
| | % | 9.7% | 69.6% | 5.1% | 2.5% | 0.4% | 11.3% | 1.4% | 100% |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 10 | 35 | 5 | 0 | 1 | 10 | 0 | 61 |
| | % | 16.4% | 57.4% | 8.2% | 0.0% | 1.6% | 16.4% | 0.0% | 100% |
| សរុប | ចំនួន | **440** | **1194** | **94** | **70** | **24** | **232** | **34** | **2088** |
| | % | **21.1%** | **57.2%** | **4.5%** | **3.4%** | **1.1%** | **11.1%** | **1.6%** | **100%** |

តាមតារាង៣.២.១ ខាងលើបានបង្ហាញឲ្យឃើញថា៖ ក្រោយការបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ និស្សិតបានធ្វើនៅក្នុងការងារឯកជនមានចំនួនច្រើនជាងគេគឺ ១១៩៤នាក់ ឬ ៥៧.៣% ។

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរ៖ និស្សិតធ្វើការងាររដ្ឋមានចំនួនច្រើនជាងគេ គឺ ២៤៦នាក់ ឬ ៤០.៣%

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេសៈ និស្សិតធ្វើការងារឯកជនមានចំនួនច្រើនជាងគេ គឺ ២១នាក់ ឬ ៣៨.៩%
- ផ្នែករដ្ឋបាលសាធារណៈៈ និស្សិតធ្វើការងាររដ្ឋមានចំនួនច្រើនជាងគេ គឺ ២៧នាក់ ឬ ៥៥%
- ផ្នែកសេដ្ឋកិច្ចៈ និស្សិតធ្វើការងារឯកជនមានចំនួនច្រើនជាងគេ គឺ ៣៣៨នាក់ ឬ ៧០.៥%
- ផ្នែកគណនេយ្យៈ និស្សិតធ្វើការងារឯកជនមានចំនួនច្រើនជាងគេ គឺ ១០២នាក់ ឬ ៧២.៣%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុៈ និស្សិតធ្វើការងារឯកជនមានចំនួនច្រើនជាងគេ គឺ ៤៨១នាក់ ឬ ៦៩.៦%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យាៈ និស្សិតធ្វើការងារឯកជនមានចំនួនច្រើនជាងគេ គឺ ៣៥នាក់ ឬ ៥៧.៤%

### ៣.២.២. ការវិភាគភាពមានការងារធ្វើ តាមភេទ និងជំនាញឯកទេស

**តារាង៣.២.២ៈ ការវិភាគភាពមានការងារធ្វើ តាមជំនាញឯកទេស**

| បរិញ្ញាបត្រ ឬជំនាញ | | ភេទ | | សរុប |
|---|---|---|---|---|
| | | ភេទប្រុស | ភេទស្រី | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 419 | 124 | **543** |
| | % | 77.2% | 22.8% | **100.0%** |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 22 | 26 | **48** |
| | % | 45.8% | 54.2% | **100.0%** |
| រដ្ឋបាលសាធារណៈ | ចំនួន | 26 | 21 | **47** |
| | % | 55.3% | 44.7% | **100.0%** |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 320 | 132 | **452** |
| | % | 70.8% | 29.2% | **100.0%** |
| គណនេយ្យ | ចំនួន | 16 | 120 | **136** |
| | % | 11.8% | 88.2% | **100.0%** |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 218 | 427 | **645** |
| | % | 33.8% | 66.2% | **100.0%** |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 42 | 13 | **55** |
| | % | 76.4% | 23.6% | **100.0%** |
| សរុប | ចំនួន | **1063** | **863** | **1926** |
| | % | **55.2%** | **44.8%** | **100.0%** |

តាមតារាង៣.២.២ ខាងលើបានបង្ហាញថាៈ ក្នុងចំណោមនិស្សិតដែលមានការងារធ្វើទាំងអស់ និស្សិតប្រុសមានការងារធ្វើចំនួន ១០៦៣នាក់ ឬ ៥៥.២% និងនិស្សិតស្រីមានការងារធ្វើចំនួន ៨៦៣នាក់ ឬ ៤៤.៨% ដែលក្នុងនោះៈ

- ផ្នែកនីតិសាស្រ្តសិក្សាជាភាសាខ្មែរៈ និស្សិតប្រុសមានការងារធ្វើចំនួន ៤១៩នាក់ ឬ ៧៧.២% និងនិស្សិតស្រីមានការងារធ្វើចំនួន ១២៤នាក់ ឬ ២២.៨%
- ផ្នែកនីតិសាស្រ្តសិក្សាជាភាសាបរទេសៈ និស្សិតប្រុសមានការងារធ្វើចំនួន ២២នាក់ ឬ ៤៥.៨% និងនិស្សិតស្រីមានការងារធ្វើចំនួន ២៦នាក់ ឬ ៥៤.២%
- ផ្នែករដ្ឋបាលសាធារណៈៈ និស្សិតប្រុសមានការងារធ្វើចំនួន ២៦នាក់ ឬ ៥៥.៣% និងនិស្សិតស្រីមានការងារធ្វើចំនួន ២១នាក់ ឬ ៤៤.៧%
- ផ្នែកសេដ្ឋកិច្ចៈ និស្សិតប្រុសមានការងារធ្វើចំនួន ៣២០នាក់ ឬ ៧០.៨% និងនិស្សិតស្រីមានការងារធ្វើចំនួន ១៣២នាក់ ឬ ២៩.២%
- ផ្នែកគណនេយ្យៈ និស្សិតប្រុសមានការងារធ្វើចំនួន ១៦នាក់ ឬ ១១.៨% និងនិស្សិតស្រីមានការងារធ្វើចំនួន ១២០នាក់ ឬ ៨៨.២%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុៈ និស្សិតប្រុសមានការងារធ្វើចំនួន ២១៨នាក់ ឬ ៣៣.៨% និងនិស្សិតស្រីមានការងារធ្វើចំនួន ៤២៧នាក់ ឬ ៦៦.២%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យាៈ និស្សិតប្រុសមានការងារធ្វើចំនួន ៤២នាក់ ឬ ៧៦.៤% និងនិស្សិតស្រីមានការងារធ្វើចំនួន ១៣នាក់ ឬ ២៣.៦%

### ៣.២.៣. ការវិភាគភាពមានការងារធ្វើ តាមភេទ និងវិស័យ

**តារាង៣.២.៣ៈ ការវិភាគភាពមានការងារធ្វើ វិភាគតាមភេទ និងវិស័យ**

| ការងារតាមវិស័យ | | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ការងាររដ្ឋ | ចំនួន | 329 | 110 | **439** |
| | % | 74.9% | 25.1% | **100.0%** |
| ការងារឯកជន | ចំនួន | 593 | 589 | **1182** |
| | % | 50.2% | 49.8% | **100.0%** |
| ការងារអង្គការ | ចំនួន | 45 | 50 | **95** |
| | % | 47.4% | 52.6% | **100.0%** |
| អាជីវកម្មផ្ទាល់ខ្លួន | ចំនួន | 111 | 113 | **224** |
| | % | 49.6% | 50.4% | **100.0%** |
| ការងារផ្សេងៗ | ចំនួន | 13 | 19 | **32** |
| | % | 40.6% | 59.4% | **100.0%** |
| សរុប | ចំនួន | **1091** | **881** | **1972** |
| | % | **55.3%** | **44.7%** | **100.0%** |

តាមតារាង៣.២.៣ ខាងលើបានបង្ហាញថាៈ តាមការវិភាគតាមវិស័យ និស្សិតប្រុសដែលមានការងារធ្វើចំនួន ១០៩១នាក់ ឬ ៥៥.៣% និងនិស្សិតស្រីដែលមានការងារធ្វើចំនួន ៨៨១នាក់ ឬ ៤៤.៧%។

- ការងាររដ្ឋ៖ និស្សិតប្រុសមានការងារធ្វើចំនួន ៣២៩នាក់ ឬ ៧៤.៩% និងនិស្សិតស្រីមានការងារធ្វើចំនួន ១១០នាក់ ឬ ២៥.១%
- ការងារឯកជន៖ និស្សិតប្រុសមានការងារធ្វើចំនួន ៥៩៣នាក់ ឬ ៥០.២% និងនិស្សិតស្រីមានការងារធ្វើចំនួន ៥៨៩នាក់ ឬ ៤៩.៨%
- ការងារអង្គការ៖ និស្សិតប្រុសមានការងារធ្វើចំនួន ៤៥នាក់ ឬ ៤៧.៤% និងនិស្សិតស្រីមានការងារធ្វើចំនួន ៥០នាក់ ឬ ៥២.៦%
- អាជីវកម្មផ្ទាល់ខ្លួន៖ និស្សិតប្រុសមានការងារធ្វើចំនួន ១១១នាក់ ឬ ៤៩.៦% និងនិស្សិតស្រីមានការងារធ្វើចំនួន ១១៣នាក់ ឬ ៥០.៤%
- ការងារផ្សេងៗ៖ និស្សិតប្រុសមានការងារធ្វើចំនួន ១៣នាក់ ឬ ៤០.៦% និងនិស្សិតស្រីមានការងារធ្វើចំនួន ១៩នាក់ ឬ ៥៩.៤%

### ៣.៣. ភាពមានការងារធ្វើត្រូវជំនាញឯកទេស ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

តារាង៣.៣.១៖ ការវិភាគភាពមានការងារធ្វើត្រូវជំនាញឯកទេស តាមជំនាញឯកទេស

| បរិញ្ញាបត្រ ឬជំនាញ | | ការងារ | | សរុប |
|---|---|---|---|---|
| | | ស្របជំនាញ | ខុសជំនាញ | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 301 | 213 | 514 |
| | % | 58.6% | 41.4% | 100.0% |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 37 | 14 | 51 |
| | % | 72.5% | 27.5% | 100.0% |
| រដ្ឋបាលសាធារណៈ | ចំនួន | 29 | 20 | 49 |
| | % | 59.2% | 40.8% | 100.0% |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 246 | 146 | 392 |
| | % | 62.8% | 37.2% | 100.0% |
| គណនេយ្យ | ចំនួន | 87 | 49 | 136 |
| | % | 64.0% | 36.0% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 388 | 225 | 613 |
| | % | 63.3% | 36.7% | 100.0% |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 24 | 32 | 56 |
| | % | 42.9% | 57.1% | 100.0% |
| សរុប | ចំនួន | 1112 | 699 | 1811 |
| | % | 61.4% | 38.6% | 100.0% |

តាមតារាង៣.៣.១ ខាងលើបានបង្ហាញថា៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ១១១២នាក់ ឬ ៦១.៤% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ៦៩៩នាក់ ឬ ៣៨.៦%។

- ផ្នែកនីតិសាស្រ្តសិក្សាជាភាសាខ្មែរ៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ៣០១នាក់ ឬ៥៨.៦% និង និស្សិតដែលធ្វើការខុសជំនាញមានចំនួន ២១៣នាក់ ឬ ៤១.៤%
- ផ្នែកនីតិសាស្រ្តសិក្សាជាភាសាបរទេស៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ៣៧នាក់ ឬ ៧២.៥% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ១៤នាក់ ឬ ២៧.៥%
- ផ្នែករដ្ឋបាលសាធារណៈ៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ២៩នាក់ ឬ ៥៩.២% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ២០នាក់ ឬ ៤០.៨%
- ផ្នែកសេដ្ឋកិច្ច៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ២៤៦នាក់ ឬ ៦២.៨% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ១៤៦នាក់ ឬ ៣៧.២%
- ផ្នែកគណនេយ្យ៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ៨៧នាក់ ឬ ៦៤.០% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ៤៩នាក់ ឬ ៣៦.០%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុ៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ៣៨៨នាក់ ឬ ៦៣.៣% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ២២៥នាក់ ឬ ៣៦.៧%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា៖ និស្សិតដែលធ្វើការត្រូវជំនាញចំនួន ២៤នាក់ ឬ ៤២.៩% និងនិស្សិតដែលធ្វើការខុសជំនាញមានចំនួន ៣២នាក់ ឬ ៥៧.១%

**តារាង៣.៣.២៖ ការវិភាគភាពមានការងារធ្វើត្រូវនឹងជំនាញឯកទេស តាមជំនាញឯកទេស និងភេទ**

| បរិញ្ញាបត្រ ឬជំនាញ | | ភេទ | | សរុប |
|---|---|---|---|---|
| | | ភេទប្រុស | ភេទស្រី | |
| នីតិសាស្រ្តជាភាសាខ្មែរ | ចំនួន | 236 | 65 | **301** |
| | % | 78.4% | 21.6% | **100.0%** |
| នីតិសាស្រ្តជាភាសាបរទេស | ចំនួន | 18 | 19 | **37** |
| | % | 48.6% | 51.4% | **100.0%** |
| រដ្ឋបាលសាធារណៈ | ចំនួន | 18 | 11 | **29** |
| | % | 62.1% | 37.9% | **100.0%** |
| វិទ្យាសាស្រ្តសេដ្ឋកិច្ច | ចំនួន | 177 | 69 | **246** |
| | % | 72.0% | 28.0% | **100.0%** |
| គណនេយ្យ | ចំនួន | 9 | 78 | **87** |
| | % | 10.3% | 89.7% | **100.0%** |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 132 | 256 | **388** |
| | % | 34.0% | 66.0% | **100.0%** |

| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 20 | 4 | **24** |
|---|---|---|---|---|
| | % | 83.3% | 16.7% | **100.0%** |
| **សរុប** | ចំនួន | **610** | **502** | **1112** |
| | % | **54.9%** | **45.1%** | **100.0%** |

តាមតារាង៣.៣.២ ខាងលើបានបង្ហាញថា៖ ក្នុងចំណោមនិស្សិតដែលមានការងារធ្វើត្រូវជំនាញ ក្នុងនោះ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ៦១០នាក់ ឬ ៥៤.៩% និងនិស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ៥០២នាក់ឬ ៤៥.១% ដែលក្នុងនោះ៖

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរ៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ២៣៦នាក់ ឬ ៧៨.៤% និងនិស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ៦៥នាក់ ឬ ២១.៦%
- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេស៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ១៨នាក់ ឬ ៤៨.៦% និងនិស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ១៩នាក់ ឬ ៥១.៤%
- ផ្នែករដ្ឋបាលសាធារណៈ៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ១៨នាក់ ឬ ៦២.១% និង និស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ១១នាក់ ឬ ៣៧.៩%
- ផ្នែកសេដ្ឋកិច្ច៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ១៧៧នាក់ ឬ ៧២.០% និងនិស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ៦៩នាក់ ឬ ២៨.០%
- ផ្នែកគណនេយ្យ៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ៩នាក់ ឬ ១០.៣% និងនិស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ៧៨នាក់ ឬ ៨៩.៧%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុ៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ១៣២នាក់ ឬ ៣៤.០% និង និស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ២៥៦នាក់ ឬ ៦៦.០%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា៖ និស្សិតប្រុសមានការងារធ្វើត្រូវជំនាញចំនួន ២០នាក់ ឬ ៨៣.៣% និង និស្សិតស្រីមានការងារធ្វើត្រូវជំនាញចំនួន ៤នាក់ ឬ ១៦.៧%

## ៣.៤. កម្រិតប្រាក់បៀវត្ស ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

### ៣.៤.១. ការវិភាគកម្រិតប្រាក់បៀវត្ស តាមភេទ

**តារាង៣.៤.១.១៖ កម្រិតប្រាក់បៀវត្សទាំងពីរភេទ**

| | កម្រិតប្រាក់បៀវត្ស | | | | | សរុប |
|---|---|---|---|---|---|---|
| | ក្រោម ១៥០$ | ១៥០$-៣០០$ | ៣០០$-៥០០$ | ៥០០$-៨០០$ | លើសពី៨០០$ | |
| **ចំនួន** | 170 | 891 | 650 | 134 | 31 | **1876** |
| **%** | 9.1% | 47.5% | 34.6% | 7.1% | 1.7% | **100.0%** |

តាមតារាង ៣.៤.១.១ បានបង្ហាញឲ្យឃើញថា៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សច្រើនជាងគេគឺនៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ៨៩១នាក់ ឬ ៤៧.៥% និងប្រាក់បៀវត្ស នៅចន្លោះ ៣០០$-៥០០$ មានចំនួន ៦៥០ នាក់ ឬ៣៤.៦% ។

**តារាង៣.៤.១.២៖ ការវិភាគកម្រិតប្រាក់បៀវត្ស តាមភេទ**

| កម្រិតប្រាក់បៀវត្ស | | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ក្រោម ១៥០$ | ចំនួន | 118 | 52 | **170** |
| | % | 69.4% | 30.6% | **100.0%** |
| ១៥០$-៣០០$ | ចំនួន | 510 | 381 | **891** |
| | % | 57.2% | 42.8% | **100.0%** |
| ៣០០$-៥០០$ | ចំនួន | 334 | 316 | **650** |
| | % | 51.4% | 48.6% | **100.0%** |
| ៥០០$-៨០០$ | ចំនួន | 73 | 61 | **134** |
| | % | 54.5% | 45.5% | **100.0%** |
| លើសពី៨០០$ | ចំនួន | 9 | 22 | **31** |
| | % | 29.0% | 71.0% | **100.0%** |

តាមតារាង ៣.៤.១.២ បានបង្ហាញឲ្យឃើញថា៖

- កម្រិតប្រាក់បៀវត្ស ក្រោម ១៥០$ ៖ និស្សិតប្រុសមានចំនួនច្រើនជាងនិស្សិតស្រី ដែលក្នុងនោះ និស្សិតប្រុសមានចំនួន ១១៨នាក់ ឬ ៦៩.៤% និងនិស្សិតស្រីមានចំនួន ៥២នាក់ ឬ ៣០.៦%
- កម្រិតប្រាក់បៀវត្ស នៅចន្លោះ ១៥០$-៣០០$ ៖ និស្សិតប្រុសមានចំនួនច្រើនជាងនិស្សិតស្រី ដែលក្នុងនោះ និស្សិតប្រុសមានចំនួន ៥១០នាក់ ឬ ៥៧.២% និងនិស្សិតស្រីមានចំនួន ៣៨១នាក់ ឬ ៤២.៨%
- កម្រិតប្រាក់បៀវត្ស នៅចន្លោះ ៣០០$-៥០០$ ៖ និស្សិតប្រុសមានចំនួនច្រើនជាងនិស្សិតស្រី ដែលក្នុងនោះ និស្សិតប្រុសមានចំនួន ៣៣៤នាក់ ឬ ៥១.៤% និងនិស្សិតស្រីមានចំនួន ៣១៦នាក់ ឬ ៤៨.៦%
- កម្រិតប្រាក់បៀវត្ស នៅចន្លោះ ៥០០$-៨០០$ ៖ និស្សិតប្រុសមានចំនួនច្រើនជាងនិស្សិតស្រី ដែលក្នុងនោះ និស្សិតប្រុសមានចំនួន ៧៣នាក់ ឬ ៥៤.៥% និងនិស្សិតស្រីមានចំនួន ៦១នាក់ ឬ ៤៥.៥%
- កម្រិតប្រាក់បៀវត្ស លើស ៨០០$ ៖ និស្សិតស្រីមានចំនួនច្រើនជាងនិស្សិតប្រុស ដែលក្នុងនោះ និស្សិត ស្រីមានចំនួន ២២នាក់ ឬ ៧១.០% និងនិស្សិតប្រុសមានចំនួន ៩នាក់ ឬ ២៩.៤% ។

### ៣.៤.២. ការវិភាគកម្រិតប្រាក់បៀវត្ស តាមជំនាញឯកទេស

តារាង៣.៤.២៖ ការវិភាគកម្រិតប្រាក់បៀវត្ស តាមជំនាញឯកទេស

| បរិញ្ញាបត្រ ឬជំនាញ | | កម្រិតប្រាក់បៀវត្ស | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ក្រោម ១៥០$ | ១៥០$-៣០០$ | ៣០០$-៥០០$ | ៥០០$-៨០០$ | លើសពី៨០០$ | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 106 | 274 | 112 | 27 | 8 | **527** |
| | % | 20.1% | 52.0% | 21.3% | 5.1% | 1.5% | **100.0%** |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 6 | 15 | 15 | 3 | 4 | **43** |
| | % | 14.0% | 34.9% | 34.9% | 7.0% | 9.3% | **100.0%** |
| រដ្ឋបាលសាធារណៈ | ចំនួន | 19 | 25 | 2 | 1 | 0 | **47** |
| | % | 40.4% | 53.2% | 4.3% | 2.1% | 0.0% | **100.0%** |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 8 | 173 | 209 | 51 | 0 | **441** |
| | % | 1.8% | 39.2% | 47.4% | 11.6% | 0.0% | **100.0%** |
| គណនេយ្យ | ចំនួន | 7 | 66 | 50 | 9 | 2 | **134** |
| | % | 5.2% | 49.3% | 37.3% | 6.7% | 1.5% | **100.0%** |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 24 | 314 | 244 | 43 | 16 | **641** |
| | % | 3.7% | 49.0% | 38.1% | 6.7% | 2.5% | **100.0%** |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 2 | 34 | 22 | 2 | 1 | **61** |
| | % | 3.3% | 55.7% | 36.1% | 3.3% | 1.6% | **100.0%** |
| សរុប | ចំនួន | **106** | **274** | **112** | **27** | **8** | **527** |
| | % | **20.1%** | **52.0%** | **21.3%** | **5.1%** | **1.5%** | **100.0%** |

តាមតារាង៣.៤.២ បានបង្ហាញឲ្យឃើញថា៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សច្រើនជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ គឺចំនួន ២៧៤នាក់ ឬ ៥២.០% ដែលក្នុងនោះ៖

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ២៧៤នាក់ ឬ ៥២.០%
- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេស៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ និង១៥០$-៣០០$ ដែលមានចំនួនស្មើគ្នាគឺ ១៥នាក់ ឬ ៣៤.៩%
- ផ្នែករដ្ឋបាលសាធារណៈ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ២៥នាក់ ឬ ៥៣.២%
- ផ្នែកសេដ្ឋកិច្ច៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ៣០០$-៥០០$ ដែលមានចំនួន ២០៩នាក់ ឬ ៤៧.៤%

- ផ្នែកគណនេយ្យ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ៦៦នាក់ ឬ ៥៤.៣%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្ស នៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ៣១៩នាក់ ឬ ៤៩.០%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សខ្ពស់ជាងគេ គឺកម្រិតប្រាក់បៀវត្ស នៅចន្លោះ ១៥០$-៣០០$ ដែលមានចំនួន ៣៨នាក់ ឬ ៥៥.៧% ។

### ៣.៤.៣. កម្រិតប្រាក់បៀវត្សនៃការងារត្រូវនឹងជំនាញឯកទេស

**តារាង៣.៤.៣៖ កម្រិតប្រាក់បៀវត្សនៃការងារត្រូវនឹងជំនាញឯកទេស**

| ការងារ និងជំនាញ | | កម្រិតប្រាក់បៀវត្ស | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ក្រោម ១៥០$ | ១៥០$-៣០០$ | ៣០០$-៥០០$ | ៥០០$-៨០០$ | លើសពី៨០០$ | |
| ការងារត្រូវនឹងជំនាញ | ចំនួន | 112 | 541 | 414 | 81 | 15 | **1163** |
| | % | 9.6% | 46.5% | 35.6% | 7.0% | 1.3% | **100.0%** |
| ការងារខុសជំនាញ | ចំនួន | 58 | 357 | 224 | 47 | 15 | **701** |
| | % | 8.3% | 50.9% | 32.0% | 6.7% | 2.1% | **100.0%** |

តាមតារាង៣.៤.៣ បានបង្ហាញឲ្យឃើញថា៖

- ចំពោះនិស្សិតដែលធ្វើការងារត្រូវនឹងជំនាញ ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សច្រើនជាងគេ គឺ កម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ គឺចំនួន ៥៤១នាក់ ឬ ៤៦.៥%
- ចំពោះនិស្សិតដែលធ្វើការងារខុសជំនាញ ៖ និស្សិតដែលមានកម្រិតប្រាក់បៀវត្សច្រើនជាងគេ គឺ កម្រិតប្រាក់បៀវត្សនៅចន្លោះ ១៥០$-៣០០$ គឺចំនួន ៣៥៧នាក់ ឬ ៥០.៩% ។

## ៣.៥. ការលើកកម្ពស់កម្រិតជីវភាព ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

**តារាង៣.៥៖ ការលើកកម្ពស់កម្រិតជីវភាព**

| បរិញ្ញាបត្រ ឬជំនាញ | | ការលើកកម្ពស់កម្រិតជីវភាព | | | សរុប |
|---|---|---|---|---|---|
| | | កម្រិតខ្ពស់ | កម្រិតមធ្យម | កម្រិតទាប | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 127 | 339 | 73 | 539 |
| | % | 23.6% | 62.9% | 13.5% | 100.0% |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 9 | 20 | 4 | 33 |
| | % | 27.3% | 60.6% | 12.1% | 100.0% |
| រដ្ឋបាលសាធារណៈ | ចំនួន | 10 | 25 | 16 | 51 |
| | % | 19.6% | 49.0% | 31.4% | 100.0% |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 96 | 332 | 15 | 443 |
| | % | 21.7% | 74.9% | 3.4% | 100.0% |

| | | | | | |
|---|---|---|---|---|---|
| គណនេយ្យ | ចំនួន | 12 | 111 | 11 | 134 |
| | % | 9.0% | 82.8% | 8.2% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 213 | 393 | 63 | 669 |
| | % | 31.8% | 58.7% | 9.4% | 100.0% |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 23 | 34 | 4 | 61 |
| | % | 37.7% | 55.7% | 6.6% | 100.0% |
| សរុប | ចំនួន | **490** | **1254** | **186** | **1930** |
| | % | **25.4%** | **65.0%** | **9.6%** | **100.0%** |

តាមតារាង៣.៥ បានបង្ហាញឲ្យឃើញថា៖ ក្រោយបញ្ចប់ការសិក្សា តាមរយៈភាពមានការងារធ្វើរបស់និស្សិត បានជួយលើកស្ទួយកម្រិតជីវភាពរបស់ខ្លួនភាគច្រើនគឺនៅកម្រិតមធ្យម គឺនិស្សិតចំនួន ១២៥៤នាក់ ឬ ៦៥.០% ដែលក្នុងនោះ៖

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរ៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ៣៣៩នាក់ ឬ ៦២.៩%
- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេស៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ២០នាក់ ឬ ៦០.៦%
- ផ្នែករដ្ឋបាលសាធារណៈ៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ២៥នាក់ ឬ ៤៩.០%
- ផ្នែកសេដ្ឋកិច្ច៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ៣៣២នាក់ ឬ ៧៤.៩%
- ផ្នែកគណនេយ្យ៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ១១១នាក់ ឬ ៨២.៨%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុ៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ៣៣៩នាក់ ឬ ៥៨.៧%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា៖ ភាពមានការងារធ្វើរបស់និស្សិត ភាគច្រើនបានជួយលើកស្ទួយនូវកម្រិតជីវភាពនៅកម្រិតមធ្យម គឺនិស្សិតមានចំនួន ៣៤នាក់ ឬ ៥៥.៧%។

## ៣.៦. និស្សិតដែលបានបន្តការសិក្សា ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រ

**តារាង៣.៦.១៖ និស្សិតដែលបានបន្តការសិក្សា**

| បរិញ្ញាបត្រ ឬជំនាញ | | ការសិក្សា | | សរុប |
|---|---|---|---|---|
| | | បន្តការសិក្សា | មិនបន្តការសិក្សា | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 223 | 404 | 627 |
| | % | 35.6% | 64.4% | 100.0% |

| | | | | |
|---|---|---|---|---|
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 27 | 32 | 59 |
| | % | 45.8% | 54.2% | 100.0% |
| រដ្ឋបាលសាធារណៈ | ចំនួន | 9 | 41 | 50 |
| | % | 18.0% | 82.0% | 100.0% |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 48 | 410 | 458 |
| | % | 10.5% | 89.5% | 100.0% |
| គណនេយ្យ | ចំនួន | 10 | 133 | 143 |
| | % | 7.0% | 93.0% | 100.0% |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 53 | 621 | 674 |
| | % | 7.9% | 92.1% | 100.0% |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 10 | 43 | 53 |
| | % | 18.9% | 81.1% | 100.0% |
| សរុប | ចំនួន | 380 | 1684 | 2064 |
| | % | 18.4% | 81.6% | 100.0% |

តាមតារាង៣.៦.១ បានបង្ហាញឲ្យឃើញថា៖ និស្សិតដែលបានបន្តការសិក្សាការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មានចំនួន ៣៨០នាក់ ឬ ១៨.៤% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៦៨៤នាក់ ឬ ៨១.៦% ដែលក្នុងនោះ៖

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរ៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ២២៣នាក់ ឬ ៣៥.៦% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤០៤នាក់ ឬ ៦៤.៤%
- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេស៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ២៧នាក់ ឬ ៤៥.៨% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៣២នាក់ ឬ ៥៤.២%
- ផ្នែករដ្ឋបាលសាធារណៈ៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៩នាក់ ឬ ១៨.០% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤១នាក់ ឬ ៨២.០%
- ផ្នែកសេដ្ឋកិច្ច៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤៨នាក់ ឬ ១០.៥% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤១០នាក់ ឬ ៨៩.៥%
- ផ្នែកគណនេយ្យ៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១០នាក់ ឬ ៧.០% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៣៣នាក់ ឬ ៩៣.០%

- ផ្នែកធនាគារ និងហិរញ្ញវត្ថុ៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៥៣ នាក់ ឬ ៧.៩% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៦២១នាក់ ឬ ៩២.១%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យា៖ និស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១០ នាក់ ឬ ១៨.៩% និងនិស្សិតដែលមិនបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៤៣នាក់ ឬ ៨១.១%។

**តារាង៣.៦.២៖ ការវិភាគនិស្សិតដែលបានបន្តការសិក្សា តាមភេទ**

| បរិញ្ញាបត្រ ឬជំនាញ | | ភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| នីតិសាស្ត្រជាភាសាខ្មែរ | ចំនួន | 173 | 50 | **223** |
| | % | 77.6% | 22.4% | **100.0%** |
| នីតិសាស្ត្រជាភាសាបរទេស | ចំនួន | 15 | 12 | **27** |
| | % | 55.6% | 44.4% | **100.0%** |
| រដ្ឋបាលសាធារណៈ | ចំនួន | 3 | 6 | **9** |
| | % | 33.3% | 66.7% | **100.0%** |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | ចំនួន | 36 | 12 | **48** |
| | % | 75.0% | 25.0% | **100.0%** |
| គណនេយ្យ | ចំនួន | 5 | 5 | **10** |
| | % | 50.0% | 50.0% | **100.0%** |
| ធនាគារ និងហិរញ្ញវត្ថុ | ចំនួន | 19 | 34 | **53** |
| | % | 35.8% | 64.2% | **100.0%** |
| សេដ្ឋកិច្ចព័ត៌មានវិទ្យា | ចំនួន | 8 | 2 | **10** |
| | % | 80.0% | 20.0% | **100.0%** |
| សរុប | ចំនួន | **259** | **121** | **380** |
| | % | **68.2%** | **31.8%** | **100.0%** |

តាមតារាង៣.៦.២ បានបង្ហាញឲ្យឃើញថា៖ ក្នុងចំណោមនិស្សិតដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្នុងនោះនិស្សិតប្រុសមានចំនួន ២៥៩នាក់ ឬ ៦៨.២% និងនិស្សិតស្រីមានចំនួន ១២១ នាក់ ឬ ៣១.៨% ដែលក្នុងនោះ៖

- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាខ្មែរៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៧៣នាក់ ឬ ៧៧.៦% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៥០នាក់ ឬ ២២.៤%
- ផ្នែកនីតិសាស្ត្រសិក្សាជាភាសាបរទេសៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៥នាក់ ឬ ៥៥.៦% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១២នាក់ ឬ ៤៤.៤%
- ផ្នែករដ្ឋបាលសាធារណៈៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៣នាក់ ឬ ៣៣.៣% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៦នាក់ ឬ ៦៦.៧%
- ផ្នែកសេដ្ឋកិច្ចៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៣៦នាក់ ឬ ៧៥.០% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១២នាក់ ឬ ២៥.០%
- ផ្នែកគណនេយ្យៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៥នាក់ ឬ ៥០.០% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៥នាក់ ឬ ៥០.០%
- ផ្នែកធនាគារ និងហិរញ្ញវត្ថុៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ១៩នាក់ ឬ ៣៥.៨% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៣៤នាក់ ឬ ៦៤.២%
- ផ្នែកសេដ្ឋកិច្ចព័ត៌មានវិទ្យាៈ និស្សិតប្រុសដែលបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ៨នាក់ ឬ ៨០.០% និងនិស្សិតស្រីដែលបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់មានចំនួន ២នាក់ ឬ ២០.០%។

# ៤. លទ្ធផលនៃការវិភាគសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

## ៤.១. ការវិភាគភាពមានការងារធ្វើ តាមមុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

តារាងទី៤.១៖ បរិញ្ញាបត្រជាន់ខ្ពស់ចំនួន៣០៣នាក់ដែលបានផ្តល់បទសម្ភាសន៍ភាពមានការងារធ្វើ

| | មុនបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | ក្រោយបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| ប្រុស | 179 | 69.6% | 199 | 70.1% |
| ស្រី | 78 | 30.4% | 85 | 29.9% |
| សរុប | 257 | 100% | 284 | 100% |

និស្សិតផ្នែកបរិញ្ញាបត្រជាន់ខ្ពស់ពេលកំពុងសិក្សាមានការងារធ្វើចំនួន២៥៧នាក់។ ក្រោយបញ្ចប់ការសិក្សាការស្វែងរកការងារបន្ថែមមានការកើនឡើងរហូតដល់២៨៤នាក់។ចំនួននេះមានការកើនឡើងចំនួន១០,៥០% បើប្រៀបធៀបនឹងពេលកំពុងសិក្សា។ ជាទូទៅបុរសរកការងារធ្វើបានចំនួន៧១,១% ច្រើនជាងនារីមានការងារធ្វើចំនួន ២៩,៩% ក្រោយពីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

## ៤.២. ការវិភាគភាពមានការងារធ្វើ តាមឯកទេស

តារាងទី៤.២៖ ការវិភាគភាពមានការងារធ្វើតាមឯកទេស

| ជំនាញ ឬឯកទេស | | មុនបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប | ក្រោយបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | | ប្រុស | ស្រី | |
| ឯកទេសនីតិឯកជន | ចំនួន | 48 | 23 | 71 | 59 | 27 | 86 |
| | % | 67.6% | 32.4% | 100.0% | 68.6% | 31.4% | 100.0% |
| ឯកទេសរដ្ឋបាលសាធារណៈ | ចំនួន | 44 | 11 | 55 | 53 | 13 | 66 |
| | % | 80.0% | 20.0% | 100.0% | 80.3% | 19.7% | 100.0% |
| ធុរកិច្ចឯកទេសហិរញ្ញវត្ថុ | ចំនួន | 51 | 20 | 71 | 51 | 20 | 71 |
| | % | 71.8% | 28.2% | 100.0% | 71.8% | 28.2% | 100.0% |
| ធុរកិច្ចឯកទេសគ្រប់គ្រង | ចំនួន | 36 | 24 | 60 | 36 | 25 | 61 |
| | % | 60.0% | 40.0% | 100.0% | 59.0% | 41.0% | 100.0% |
| សរុប | ចំនួន | 179 | 78 | 257 | 199 | 85 | 284 |
| | % | 69.6% | 30.4% | 100.0% | 70.1% | 29.9% | 100.0% |

ភាពមានការងារធ្វើតាមជំនាញ នីតិឯកទេសរដ្ឋបាលសាធារណៈជាបុរស រក្សាភាពនាំមុខក្នុងការរកបានការងារធ្វើប្រមាណ៨០% បើប្រៀបធៀបនឹងឯកទេសនីតិឯកជនទទួលបានការងារធ្វើជាង៦៨% នៅក្រោយបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់។ ចំណែកជំនាញធុរកិច្ចឯកទេសហិរញ្ញវត្ថុជាបុរសក៏រក្សាភាពនាំមុខក្នុងការរកបានការងារធ្វើ៧១,៨% បើប្រៀបធៀបនឹងធុរកិច្ចឯកទេសគ្រប់គ្រងសហគ្រាសទទួលបានការងារធ្វើ៥៩% នៅក្រោយបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់។

## ៤.៣. ការវិភាគភាពមានការងារធ្វើ តាមវិស័យ

តារាងទី៤.៣៖ ភាពមានការងារធ្វើក្នុងស្ថាប័នផ្សេងៗ

| ការងារតាមវិស័យ | | មុនបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប | ក្រោយបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | | ប្រុស | ស្រី | |
| ការងាររដ្ឋ | ចំនួន | 83 | 27 | 110 | 98 | 30 | 128 |
| | % | 75.5% | 24.5% | 100.0% | 76.6% | 23.4% | 100.0% |
| ការងារឯកជន | ចំនួន | 69 | 36 | 105 | 74 | 38 | 112 |
| | % | 65.7% | 34.3% | 100.0% | 66.1% | 33.9% | 100.0% |
| ការងារអង្គការ | ចំនួន | 11 | 12 | 23 | 12 | 12 | 24 |
| | % | 47.8% | 52.2% | 100.0% | 50.0% | 50.0% | 100.0% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| និស្សិត | ចំនួន | 1 | 0 | 1 | - | - | - |
| | % | 100.0% | 0.0% | 100.0% | - | - | - |
| អាជីវកម្មផ្ទាល់ខ្លួន | ចំនួន | 7 | 1 | 8 | 9 | 1 | 10 |
| | % | 87.5% | 12.5% | 100.0% | 90.0% | 10.0% | 100.0% |
| ការងារផ្សេងៗ | ចំនួន | 6 | 2 | 8 | 6 | 4 | 10 |
| | % | 75.0% | 25.0% | 100.0% | 60.0% | 40.0% | 100.0% |
| សរុប | ចំនួន | 177 | 78 | 255 | 199 | 85 | 284 |
| | % | 69.4% | 30.6% | 100.0% | 70.1% | 29.9% | 100.0% |

ទាំងមុនពេលបញ្ចប់ និងក្រោយពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ការប្រកបអាជីវកម្មផ្ទាល់ខ្លួននៅតែមានភាពនាំមុខគេជាពិសេសបុរស ហើយការចូលបម្រើកិច្ចការរដ្ឋមានចំនួន ៧៦,៦% រត់តាមពីក្រោយអាជីវកម្មផ្ទាល់ខ្លួន ៩០,០% ជាបុរស។

## ៤.៤. ការវិភាគកម្រិតប្រាក់បៀវត្ស

### ៤.៤.១. ការវិភាគកម្រិតប្រាក់បៀវត្ស មុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

តារាងទី៤.៤.១ ការវិភាគកម្រិតប្រាក់បៀវត្ស មុន និងក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

| កម្រិតប្រាក់បៀវត្ស | | មុនបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប | ក្រោយបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ | | សរុប |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | | ប្រុស | ស្រី | |
| ក្រោម ១៥០$ | ចំនួន | 2 | 2 | 4 | 2 | 2 | 4 |
| | % | 50.0% | 50.0% | 100.0% | 50.0% | 50.0% | 100.0% |
| ចន្លោះ ១៥០$ -៣០០$ | ចំនួន | 53 | 19 | 72 | 68 | 22 | 90 |
| | % | 73.6% | 26.4% | 100.0% | 75.6% | 24.4% | 100.0% |
| ចន្លោះ ៣០០$ -៥០០$ | ចំនួន | 28 | 18 | 46 | 28 | 19 | 47 |
| | % | 60.9% | 39.1% | 100.0% | 59.6% | 40.4% | 100.0% |
| ចន្លោះ ៥០០$ -៨០០$ | ចំនួន | 35 | 19 | 54 | 37 | 19 | 56 |
| | % | 64.8% | 35.2% | 100.0% | 66.1% | 33.9% | 100.0% |
| ច្រើនជាង ៨០០$ | ចំនួន | 35 | 14 | 49 | 35 | 15 | 50 |
| | % | 71.4% | 28.6% | 100.0% | 70.0% | 30.0% | 100.0% |
| សរុប | ចំនួន | 153 | 72 | 225 | 170 | 77 | 247 |
| | % | 68.0% | 32.0% | 100.0% | 68.8% | 31.2% | 100.0% |

ការទទួលបានប្រាក់បៀវត្សខ្ពស់ចន្លោះ៥០០$ -៨០០$ និងច្រើនជាង ៨០០$ បុរសមានកំណើនខ្លាំងពីចំនួន ៦៤,៨% ទៅ ៧០,០% ជាងនារីហាក់នៅទ្រឹងក្នុងរង្វង់ ៣០,០%

### ៤.៤.២. ការវិភាគកម្រិតប្រាក់បៀវត្ស តាមការងារត្រូវជំនាញ និងខុសជំនាញ

តារាងទី៤.៤.២ ប្រាក់បៀវត្សក្នុងស្ថានភាពមានការងារធ្វើត្រូវជំនាញដែលបានសិក្សានៅ សភនវស

| កម្រិតប្រាក់បៀវត្ស | | បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់មានការងារត្រូវជំនាញ | | សរុប |
|---|---|---|---|---|
| | | ត្រូវតាមជំនាញ | ខុសជំនាញ | |
| ក្រោម ១៥០$ | ចំនួន | 3 | 2 | 5 |
| | % | 60.0% | 40.0% | 100.0% |
| ចន្លោះ ១៥០$ -៣០០$ | ចំនួន | 80 | 10 | 90 |
| | % | 88.9% | 11.1% | 100.0% |
| ចន្លោះ ៣០០$ -៥០០$ | ចំនួន | 46 | 2 | 48 |
| | % | 95.8% | 4.2% | 100.0% |
| ចន្លោះ ៥០០$ -៨០០$ | ចំនួន | 54 | 2 | 56 |
| | % | 96.4% | 3.6% | 100.0% |
| ច្រើនជាង ៨០០$ | ចំនួន | 51 | 0 | 51 |
| | % | 100.0% | 0.0% | 100.0% |
| សរុប | ចំនួន | 234 | 16 | 250 |
| | % | 93.6% | 6.4% | 100.0% |

ក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និស្សិតធ្វើការត្រូវជំនាញមានចំនួន៩៣,៦% និងខុសជំនាញមានចំនួន៦,៤%។ កម្រិតប្រាក់បៀវត្សដែលធ្វើការត្រូវតាមជំនាញចំនួន ១៥០$ ទៅច្រើនជាង ៨០០$ មានចំនួនភាគរយកើនខ្លាំង ពី៦០,០% ដល់កម្រិតជិត១០០%។ ចំពោះការងារដែលមានប្រាក់បៀវត្សកាន់តែខ្ពស់គឺទាមទារឲ្យមានសញ្ញាបត្រជំនាញជាក់លាក់។ផ្ទុយមកវិញ ការងារដែលមានប្រាក់បៀវត្សទាបអាចប្រើប្រាស់កម្លាំងពលកម្មមិនសូវត្រូវជំនាញបាន។

### ៤.៤.៣. ការវិភាគកម្រិតប្រាក់បៀវត្ស នៃការងារត្រូវជំនាញ និងភេទ

តារាងទី៤.៤.៣ ប្រាក់បៀវត្សក្នុងស្ថានភាពមានការងារធ្វើត្រូវជំនាញ និងតាមភេទដែលបានសិក្សានៅសភនវស

| កម្រិតប្រាក់បៀវត្ស | | បញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់មានការងារត្រូវជំនាញ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ក្រោម ១៥០$ | ចំនួន | 1 | 2 | 3 |
| | % | 33.3% | 66.7% | 100.0% |

| | | | | |
|---|---|---|---|---|
| ចន្លោះ ១៥០$ -៣០០$ | ចំនួន | 62 | 18 | 80 |
| | % | 77.5% | 22.5% | 100.0% |
| ចន្លោះ ៣០០$ -៥០០$ | ចំនួន | 26 | 18 | 44 |
| | % | 59.1% | 40.9% | 100.0% |
| ចន្លោះ ៥០០$ -៨០០$ | ចំនួន | 36 | 18 | 54 |
| | % | 66.7% | 33.3% | 100.0% |
| ច្រើនជាង ៨០០$ | ចំនួន | 36 | 15 | 51 |
| | % | 70.6% | 29.4% | 100.0% |
| សរុប | ចំនួន | 161 | 71 | 232 |
| | % | 69.4% | 30.6% | 100.0% |

ក្នុងចំណោមនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ដែលមានការងារធ្វើត្រូវតាមជំនាញដែលបានសិក្សានៅ **សភនវស** មានចំនួនសរុប ២៣២នាក់ មាន៦៩,៤%ជាបុរស និងនារីចំនួន៣០,៦%។ ចំនួនបុរសដែលមានកម្រិតប្រាក់បៀវត្សរ៍កើនឡើងពី១៥០$ ទៅច្រើនជាង ៨០០$ មានចំនួនកើនពី ៣៣,៣% ទៅ ៧០,៦%។ ចំណែកចំនួននារីមានដែលមានកម្រិតប្រាក់បៀវត្សរ៍កើនឡើងពី១៥០$ ទៅច្រើនជាង ៨០០$ មានចំនួនថយចុះពី ៦៦,៧% មកត្រឹម ២៩,៤%។

## ៤.៥. ការវិភាគភាពមានការងារធ្វើត្រូវជំនាញ និងភេទ

**តារាងទី៤.៥ ភាពមានការងារធ្វើត្រូវតាមជំនាញនីមួយៗបែងចែកទៅតាមភេទ**

| ជំនាញ ឬឯកទេស | | ភាពមានការងារធ្វើទៅតាមភេទ | | សរុប |
|---|---|---|---|---|
| | | ប្រុស | ស្រី | |
| ឯកទេសនីតិឯកជន | ចំនួន | 51 | 23 | 74 |
| | % | 68.9% | 31.1% | 100.0% |
| ឯកទេសរដ្ឋបាលសាធារណៈ | ចំនួន | 49 | 12 | 61 |
| | % | 80.3% | 19.7% | 100.0% |
| ធុរកិច្ចឯកទេសហិរញ្ញវត្ថុ | ចំនួន | 49 | 19 | 68 |
| | % | 72.1% | 27.9% | 100.0% |
| ធុរកិច្ចឯកទេសគ្រប់គ្រង | ចំនួន | 34 | 24 | 58 |
| | % | 58.6% | 41.4% | 100.0% |
| សរុប | ចំនួន | 183 | 78 | 261 |
| | % | 70.1% | 29.9% | 100.0% |

ការទទួលបានការងារធ្វើត្រូវតាមជំនាញដែលបានសិក្សានៅ សភនវស ផ្នែកបុរសមានចំនួនជាង២ដង ច្រើនជាងចំនួននារីដែលទទួលបានការងារធ្វើត្រូវតាមជំនាញ(បុរស ៧០,១% នារី ២៩,៩%)។

## ៤.៦. ការវិភាគលើការរៀនបន្តរបស់និស្សិតក្រោយបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

តារាងទី៤.៦ ការរៀនបន្តក្រោយបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់

| | ចំនួន | ភាគរយ | ភាគរយបូកបន្ត |
|---|---|---|---|
| បណ្ឌិត | 5 | 1.8% | 1.8% |
| វគ្គបំប៉នរយៈពេលខ្លី | 21 | 7.6% | 9.4% |
| សិក្សាឯកទេស | 20 | 7.2% | 16.5% |
| មិនបានសិក្សាបន្ត | 232 | 83.5% | 100.0% |
| សរុប | 278 | 100.0% | |

ក្នុងចំណោមនិស្សិត២៧៨នាក់ដែលបានឆ្លើយសំណួរលើការសិក្សាបន្ត មានចំនួន៤៦នាក់ ស្មើចំនួន១៦,៥% ដែលបានរៀនបន្តលើឯកទេសផ្សេងៗ ដែលក្នុងនោះមាន៥នាក់រៀនបណ្ឌិតស្មើនឹង១,៨%។

# ៥. សន្និដ្ឋាន

តាមរយៈការអង្កេត ដោយសម្ភាសន៍និស្សិតបរិញ្ញាបត្រក្នុងឆ្នាំសិក្សា២០១២-២០១៣ និងនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ក្នុងឆ្នាំសិក្សា២០១៣-២០១៤ ដែលមាននិស្សិតសរុបចំនួន ២៧៥២ នាក់ ដែលក្នុងនោះមាននិស្សិតថ្នាក់បរិញ្ញាបត្រចំនួន ២២៦៧ នាក់ និងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៣០៣ នាក់ ។ ជាលទ្ធផលបង្ហាញថា និស្សិតថ្នាក់បរិញ្ញាបត្រ មុនពេលចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មានការងារធ្វើតែចំនួន ១៥% ប៉ុន្តែក្រោយពេលដែលនិស្សិតបានបញ្ចប់ការសិក្សា គឺចំនួនអ្នកមានការងារធ្វើបានកើនឡើងខ្លាំងដល់ ៩៥.៥%។ ដោយឡែកនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មុនពេលចូលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ ចំនួនអ្នកមានការងារធ្វើ ៨៤.៦% ក្រោយពេលបញ្ចប់ការសិក្សា ចំនួនអ្នកមានការងារធ្វើបានកើនឡើងដល់ ៩៥.៧%។

លទ្ធផលទាំងនេះ បង្ហាញឲ្យឃើញថា ការបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានប្រសិទ្ធភាព និងគុណភាពដែលអាចឆ្លើយតបនឹងតម្រូវការធនធានមនុស្សក្នុងទីផ្សារការងារ។

លទ្ធផលនេះគឺជាការខិតខំប្រឹងប្រែងរបស់សាកលវិទ្យាល័យ ជាពិសេសគឺការខិតខំប្រឹងប្រែងរបស់អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ មន្ត្រីរាជការ សាស្ត្រាចារ្យជាតិ និងអន្តរជាតិ រួមទាំងបុគ្គលិកទាំងក្របខ័ណ្ឌ និងវេលាកាទាំងអស់របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

# ឧបសម្ព័ន្ធ១

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

អ្នកធ្វើសម្ភាសន៍៖……………………

## កម្រងសំណួរ

កម្រងសំណួរនេះ មានគោលបំណងស្វែងរកព័ត៌មាននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លទ្ធផលនៃកម្រងសំណួរនេះត្រូវបានប្រើសម្រាប់ការអភិវឌ្ឍគុណភាពអប់រំ ដើម្បីឲ្យស៊ីគ្នាទៅនឹងតម្រូវការនៃការអភិវឌ្ឍទីផ្សារ និងសង្គម។ សូមនិស្សិតម្នាក់ៗឆ្លើយដោយស្មោះត្រង់ទៅតាមការជាក់ស្តែងដែលខ្លួនបានជួបប្រទះ។

ព័ត៌មានរបស់និស្សិតម្នាក់ៗនឹងត្រូវបានរក្សាជាការសម្ងាត់។ សូមអរគុណនូវកិច្ចសហការរបស់និស្សិត។ សូមគូស(✓)ត្រង់លេខដែលជាចម្លើយរបស់និស្សិត។

ឈ្មោះនិស្សិត៖…………………… ភេទ៖ 1.☐ ប្រុស 2.☐ ស្រី

លេខទូរស័ព្ទ៖………................ Email:…………………………………………… ថ្ងៃសម្ភាស៖………………

ជំនាន់ទី៖……. បរិញ្ញាបត្រ(ជំនាញ) 1.☐ នីតិសាស្ត្រ (ខេមរៈភាសា)
2.☐ នីតិសាស្ត្រ (ភាសាអង់គ្លេស)
3.☐ រដ្ឋបាលសាធារណៈ
4.☐ សេដ្ឋកិច្ច
5.☐ គណនេយ្យ
6.☐ ធនាគារ និងហិរញ្ញវត្ថុ
7.☐ សេដ្ឋកិច្ចព័ត៌មានវិទ្យា
8.☐ គ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច

១. មុនពេលចូលរៀនថ្នាក់បរិញ្ញាបត្រនៅ RULE តើអ្នកបានធ្វើការងារអ្វី?
1.☐ការងាររដ្ឋ 2.☐ការងារឯកជន 3.☐ការងារអង្គការ 4.☐ អត់ការងារ 5.☐និស្សិត
6.☐ អាជីវកម្មផ្ទាល់ខ្លួន 7.☐ ផ្សេងៗ

២. តើបច្ចុប្បន្ន អ្នកមានការងារឬនៅ?
1.☐មានការងារ 2.☐មិនមានការងារ

៣. តើអ្នកធ្វើការត្រូវមុខជំនាញដែលបានសិក្សានៅ RULE ដែរឬទេ?
1.☐ត្រូវមុខជំនាញ 2.☐មិនត្រូវមុខជំនាញ

៤. តើអ្នកកំពុងធ្វើការងារអ្វី?
1.☐ការងាររដ្ឋ 2.☐ការងារឯកជន 3.☐ការងារអង្គការ 4.☐ អត់ការងារ 5.☐និស្សិត
6.☐ អាជីវកម្មផ្ទាល់ខ្លួន 7.☐ ផ្សេងៗ

៥. បច្ចុប្បន្ន តើស្ថានភាពប្រាក់បៀវត្សប្រចាំខែរបស់អ្នកយ៉ាងដូចម្តេច?
1.☐ក្រោម១៥០$ 2.☐១៥០$-៣០០$ 3.☐៣០០$-៥០០$ 4.☐៥០០$-៨០០$ 5.☐លើសពី៨០០$

៦. តើក្រោយពីបញ្ចប់ការសិក្សានៅ RULE អ្នកបានបន្តការសិក្សាអ្វីផ្សេងទៀតដែរឬទេ?
1.☐សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ 2.☐វគ្គបំប៉នរយៈពេលខ្លី 3.☐សិក្សាឯកទេស 4.☐មិនបានបន្ត

៧. ជារួម តើការសិក្សានៅ RULE បានជួយអ្នកដូចម្តេចខ្លះ?
1.☐លើកម្ពស់ជីវភាពបានល្អ 2.☐លើកម្ពស់ជីវភាពបានមធ្យម 3.☐លើកម្ពស់ជីវភាពបានតិចតួច

៨. ចំណុចត្រង់ណាខ្លះ ដែលអ្នកគិតថា RULE នៅខ្វះខាតខ្លាំង?

…………………………………………………………………………………………………………

៩. តើអ្នកមានសំណូមពរអ្វីខ្លះ សម្រាប់ការអភិវឌ្ឍការអប់រំនៅ RULE ?

…………………………………………………………………………………………………………

# ឧបសម្ព័ន្ធ២

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

អ្នកធ្វើសម្ភាសន៍:……………………

## កម្រងសំណួរ

កម្រងសំណួរនេះ មានគោលបំណងស្វែងរកព័ត៌មាននិស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ លទ្ធផលនៃកម្រងសំណួរនេះត្រូវបានប្រើសម្រាប់ការអភិវឌ្ឍគុណភាពអប់រំ ដើម្បីឲ្យស៊ីគ្នាទៅនឹងតម្រូវការនៃការអភិវឌ្ឍទីផ្សារ និងសង្គម។ សូមនិស្សិតម្នាក់ៗឆ្លើយដោយស្មោះត្រង់ទៅតាមការជាក់ស្តែងដែលខ្លួនបានជួបប្រទះ។

ព័ត៌មានរបស់និស្សិតម្នាក់ៗនឹងត្រូវបានរក្សាជាការសម្ងាត់។ សូមអរគុណនូវកិច្ចសហការរបស់និស្សិត។ សូមគូស(✓)ត្រង់លេខដែលជាចម្លើយរបស់និស្សិត។

ឈ្មោះនិស្សិត:…………………… ភេទ: 1. ☐ ប្រុស 2. ☐ ស្រី

លេខទូរស័ព្ទ:………................. Email:……………………………………………… ថ្ងៃសម្ភាស:………………

ជំនាន់ទី:………... បរិញ្ញាបត្រជាន់ខ្ពស់ 1. ☐ ឯកទេសនីតិឯកជន
2. ☐ ឯកទេសរដ្ឋបាលសាធារណ:
3. ☐ ធុរកិច្ច ឯកទេសហិរញ្ញវត្ថុ
4. ☐ ធុរកិច្ច ឯកទេសគ្រប់គ្រង

១. មុនពេលចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅ RULE តើអ្នកបានធ្វើការងារអ្វី?
1.☐ការងាររដ្ឋ 2.☐ ការងារឯកជន 3.☐ ការងារអង្គការ 4.☐ អត់ការងារ 5.☐ និស្សិត
6.☐អាជីវកម្មផ្ទាល់ខ្លួន 7.☐ ផ្សេងៗ

២. តើបច្ចុប្បន្ន អ្នកមានការងារឬនៅ?
1.☐មានការងារ 2.☐មិនមានការងារ

៣. តើអ្នកធ្វើការត្រូវមុខជំនាញដែលបានសិក្សានៅ RULE ដែរឬទេ?
1.☐ ត្រូវមុខជំនាញ 2.☐ មិនត្រូវមុខជំនាញ

៤. តើអ្នកកំពុងធ្វើការងារអ្វី?
1.☐ការងាររដ្ឋ 2.☐ ការងារឯកជន 3.☐ ការងារអង្គការ 4.☐ អត់ការងារ 5.☐ និស្សិត
6.☐ អាជីវកម្មផ្ទាល់ខ្លួន 7.☐ ផ្សេងៗ

៥. បច្ចុប្បន្ន តើស្ថានភាពប្រាក់បៀវត្សប្រចាំខែរបស់អ្នកយ៉ាងដូចម្តេច?
1.☐ក្រោម១៥០$ 2.☐១៥០$-៣០០$ 3.☐៣០០$-៥០០$ 4.☐៥០០$-៨០០$ 5.☐លើសពី៨០០$

៦. តើក្រោយពីបញ្ចប់ការសិក្សានៅ RULE អ្នកបានបន្តការសិក្សាអ្វីផ្សេងទៀតដែរឬទេ?
1.☐សិក្សាថ្នាក់បណ្ឌិត 2.☐វគ្គបំប៉នរយ:ពេលខ្លី 3.☐សិក្សាឯកទេស 4.☐មិនបានបន្ត

៧. ជារួម តើការសិក្សានៅ RULE បានជួយអ្នកដូចម្តេចខ្លះ?
1.☐លើកម្ពស់ជីវភាពបានល្អ 2.☐លើកម្ពស់ជីវភាពបានមធ្យម 3.☐ លើកម្ពស់ជីវភាពបានតិចតួច

៨. ចំណុចត្រង់ណាខ្លះ ដែលអ្នកគិតថា RULE នៅខ្វះខាតខ្លាំង?

……………………………………………………………………………………………………………….

៩. តើអ្នកមានសំណូមពរអ្វីខ្លះ សម្រាប់ការអភិវឌ្ឍការអប់រំនៅ RULE ?

………………………………………………………………………………………………………………..